MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**សម្រាប់ទិវា អ៊ីនធឺណិតដែលមានសុវត្ថិភាពជាងមុន**
**ថ្ងៃអង្គារ៍ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៥**
**"ចូរ យើង ភ្ជាប់ទៅអ៊ីនធឺណិតមួយដែលមាន សុវត្ថិភាព ដែលផ្តល់សិទ្ធិអំណាច និងមានលក្ខណៈទូលំទូលាយ"**

ទីក្រុងហ្សឺណែវ (៩ កុម្ភៈ ២០១៥) - អ្នកជំនាញកំពូលខាងសិទ្ធិកុមារ និងសេរីភាពនៃការបញ្ចេញមតិ ចូលរួមបញ្ចេញមតិយោបល់ពីកុមារ មាតាបិតា គ្រូបង្រៀន អ្នកធ្វើគោលនយោបាយ ការ អនុវត្តច្បាប់ ឧស្សាហកម្ម និងសង្គមស៊ីវិល ក្នុងការអំពាវនាវរបស់ពួកគេឲ្យមានការបង្កើតអ៊ីនធឺណិតមួយដែលល្អប្រសើរជាងមុន និងមានសុវត្ថិភាព។

មានប្រសាសន៍នៅក្នុងឱកាសនៃទិវាអន្តរជាតិស្តីពីអ៊ីនធឺណិតមានសុវត្ថិភាពជាងមុន លោកស្រី ម៉ារតា សានតូស ផេស (*Marta Santos Pais)* តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ លោកស្រី មូដ ឌឺ បូរ៉េអ៊ែ ប៊ូគីជីអូ ( *Maud de Boer-Buquicchio)* អ្នករាយការណ៍ពិសេសស្តីពីការលក់ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងលោក ដេវីដ កៃអ៊ី ( *David Kaye)* អ្នករាយការណ៍ពិសេសស្តីពីសេរីភាពនៃការបញ្ចេញមតិ ធ្វើការអំពាវនាវដល់រដ្ឋនានា និងឧស្សាហកម្មបច្ចេកវិទ្យាព័ត៌មាន ឲ្យធ្វើការដោះស្រាយដោយផ្ទាល់តាមបណ្តាញអ៊ីនធឺណិតចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ទន្ទឹមនឹងនេះក៏ ត្រូវការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់កុមារ និងនីតិជនផងដែរ ។

"បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង មានការវិវត្ត និងរីក សាយក្នុងសន្ទុះមួយដ៏គួរឲ្យចាប់អារម្មណ៍ ។ ការវិវត្តនេះបង្ហាញអំពីឱកាសដ៏អស្ចារ្យមួយ ដែលកុមារកាន់តែច្រើនឡើងៗ បាននិងកំពុងប្រើប្រាស់ ដើម្បីរៀនសូត្រ លេង បង្កើត ទំនាក់ទំនងគ្នាតាមបណ្តាញសង្គម ព្រមទាំង បញ្ចេញមតិរបស់ខ្លួន ជាពិសេស តាមរយៈអ៊ីនធឺណិត។ ពិតណាស់ តាមរយៈការប្រើប្រាស់អ៊ីនធឺណិតរបស់ពួកគេ កុមារនោះអាចអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការទទួលព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ សិទ្ធិរបស់កុមារនឹងត្រូវបានគេស្តាប់ ចូលរួមតស៊ូមតិជាសាធារណៈ និងបង្កើតគំនិតរិះគន់ផ្សេងៗ ។

ទោះជាយ៉ាងណាក៏ដោយ ប្រសិនមិនមានចំណាត់ការដាច់ខាត និងមានការសម្របសម្រួលទេនោះ កុមាររាប់លាននាក់នឹងនៅតែបន្តត្រូវបានគេផាត់ចេញពីការទទួលបានអត្ថប្រយោជន៍ពីអ៊ីនធឺណិត កុមាររងគ្រោះពីអំពើហិង្សាតាមបណ្តាញអ៊ីនធឺណិត ការរំលោបំពាន និងការកេងប្រវ័ញ្ចនឹងនៅតែបន្តកើនឡើងច្រើន ហើយនិទណ្ឌភាពចំពោះអំពើល្មើសទាំងនេះនឹងនៅតែបន្តបង្កឲ្យមានបទឧក្រិដ្ឋ។

ភាពបើកចំហរ និងភាពអាចប្រើប្រាស់បាននូវសិទ្ធិជាមូលដ្ឋាននៃអ៊ីនធឺណិត ប៉ុន្តែនៅក្នុងនោះក៏មានហានីភ័យខ្លាំងបំផុតមួយចំនួនផងដែរ។ បច្ចេកវិទ្យាថ្មីៗ បាននិងកំពុងផ្តល់ភាពងាយស្រួលដល់ការផលិត និងការរីកសាយយ៉ាងឆាប់រហ័សនូវឯកសារសម្ភាររំលោភបំពានលើកុមារ ជាមួយនឹងសកម្មភាពកេងប្រវ័ញ្ចថ្មីៗជាច្រើន បានលេចឡើង ដូចជា ការបញ្ជូន ឬទទួលរូបភាពវីដេអូ ឬសោតទស្សន៍ដោយផ្ទាល់តាមតម្រូវការនូវការរំលោភបំពានផ្លូវភេទលើកុមារ។ ការកម្រិតកំណត់ពីបរិមាណ និង អត្តសញ្ញាណនៃករណីផ្សេងៗមានការលំបាកដោយសារតែការអាចមានការបិទបាំងសកម្មភាពល្មើសច្បាប់នៅលើអ៊ីនធឺណិត។ គ្រោះថ្នាក់ដែលបានបង្កឡើងចំពោះកុមាររងគ្រោះ កាន់តែកើនឡើង នៅពេលរូបភាពនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចនោះ ត្រូវបានគេដឹងតៗគ្នា ។

ការលាតត្រដាងព័ត៌មានគ្រោះថ្នាក់ ឬសម្ភាររំលោភបំពាន បង្កឡើងដោយអ្នកកេងប្រវ័ញ្ចជនល្មើស ការរំលោភសិទ្ធិឯកជន ការគំរាមតាមអ៊ីនធឺណិត និងការផលិត និងចែកចាយ សកម្មភាពកេងប្រវ័ញ្ច មិនអាចជាផលវិបាកដែលកើតចេញពីការបញ្ចូលរបៀបថ្មី និងសេរីភាពឡើយ។

ដោយសារតែបច្ចេកវិទ្យាមានការវិវត្ត រដ្ឋមួយចំនួនបានដាក់ការរិតត្បិតវិសមាមាត្រលើសេរីភាពនៃការបញ្ចេញមតិលើអ៊ីនធឺណិត ដោយបង្ហាញថាវាគឺជាវិធានការក្នុងការការពារកុមារមិនឲ្យមានគ្រោះថ្នាក់ ដែល តាមពិតទៅ រដ្ឋទាំងនោះដាក់កម្រិតលើសិទ្ធិកុមារ និងនីតិជន ទៅវិញទេ។ ការការពារកុមារ និងសេរីភាពនៃការបញ្ចេញមតិ មិនត្រូវបានដោះស្រាយជាគោលដៅផ្ទុយឡើយ។

ផ្ទុយមកវិញ បញ្ហាប្រឈមនៃការបង្កើតឲ្យមានបរិស្ថានមួយតាមអ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារស្ថិតលើការបង្កើតឲ្យមានការឆ្លើយតបជាច្រើនដែលធ្វើឲ្យសម្រេចបាននូវតុល្យភាពត្រឹមត្រូវរវាងការបង្កើតជាអតិបរមាកម្មនូវសក្តានុពលនៃបច្ចេកវិទ្យាថ្មីដើម្បីលើកស្ទួយ និងការពារសិទ្ធិកុមារ ទន្ទឹមនឹងនេះ ក៏ត្រូវកាត់បន្ថយហានីភ័យដល់កម្រិតអប្បបរមា ព្រមទាំងធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមារផងដែរ។ វាជាងការកាត់បន្ថយភាពចង់ដឹងចង់ឮជាធម្មជាតិរបស់កុមារ និងសញ្ញាណនៃ ការបញ្ចូលរបៀបថ្មី ដោយមានភ័យខ្លាចជួបនូវហានីភ័យតាមអ៊ីនធឺណិត ចាំបាច់ត្រូវយល់អំពីការបង្កើតរបស់វា និងបង្កើនសមត្ថភាពរបស់វា ក្នុងការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយប្រសិទ្ធភាព។

វឌ្ឍនភាព ខ្លាំងដែលសម្រេចបានក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះក្នុងការដោះស្រាយហានីភ័យ និងគ្រោះថ្នាក់ផ្សេងៗទន្ទឹមនឹងការបង្កើនកាលានុវត្តភាពជាអតិបរមាតាមរយៈបច្ចេកវិទ្យាថ្មីៗ ដើម្បីបង្ការ ទប់ស្កាត់ការរំលោភបំពានតាមអ៊ីនធឺណិត និងផ្តល់សិទ្ធិអំណាចដល់កុមារ តាមរយៈការផ្សព្វផ្សាយការយល់ដឹង កម្មវិធីអប់រំ និងការបណ្តុះបណ្តាលឯកទេស ដោយផ្តោតការយកចិត្តទុកដាក់លើសាលារៀន និងគាំទ្រដល់មាតាបិតា និង អាណាព្យាបាលក្នុងចំណោមអ្នកដទៃផ្សេងទៀត។

វាគឺជាពេលវេលាដ៏សក្តិសមក្នុងការបង្កើនកិច្ចខិតខំប្រឹងប្រែងទាំងនេះ ដោយភ្ជាប់ទំនាក់ទំនងតាមរយៈ សម្ព័ន្ធភាពជាសកលពិតប្រាកដមួយ ដើម្បីបង្កើតរបៀបវារៈឌីជីថលដែលផ្តល់សិទ្ធិអំណាច ដែលមានសុវត្ថិភាព និងមានលក្ខណៈទូលំទូលាយ។

យើងសូមអំពាវនាវដល់រដ្ឋទាំងឡាយឲ្យបង្កើតនូវក្របខ័ណ្ឌគតិយុត្តមួយទូលំទូលាយ និង ច្បាស់លាស់ ដើម្បីធានាឲ្យមានការហាមប្រាមច្បាស់លាស់តាមគ្រប់រូបភាពនៃអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ រាប់ទាំងនៅក្នុងលំហរអ៊ិនធឺណិត ក៏ដូចជា ការ លើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មានរបស់កុមារ។ រដ្ឋទាំងឡាយ ត្រូវដាក់ទុនក្នុងកម្មវិធីបង្ការ និងរក្សាឲ្យហ្មត់ចត់នូវការការពារប្រកបដោយប្រសិទ្ធភាព ការដោះស្រាយសំណងដល់កុមាររងគ្រោះ។

យើងខ្ញុំសូមអំពាវនាវដល់រដ្ឋទាំងឡាយ ឧស្សាហកម្ម និងសង្គមស៊ីវិល ឲ្យបង្កើត យន្តការត្រួតពិនិត្យតាមដាន និងរាយការណ៍មានលក្ខណៈកុមារមេត្រី រួមទាំងខ្សែទូរស័ព្ទផ្តល់ព័ត៌មានទាន់ហេតុការណ៍ដើម្បីអាចទទួលបាននូវដំបូន្មាន និងការអនុវត្ត ដើម្បីរាយការណ៍ពីឧប្បត្តិហេតុហិង្សាទាំងឡាយ និងសកម្មភាពដែលគួរឲ្យសង្ស័យ។ សេវាអ៊ីនធឺណិត និងអ្នកសរសេរមាតិការឿងលើអ៊ីនធឺណិត ព្រមទាំងក្រុមហ៊ុនបច្ចេកវិទ្យា គួរតែជួយកំណត់អត្តសញ្ញាណជនរងគ្រោះ និងជនល្មើស ហើយគួរតែដក ឯកសារសម្ភាររំលោភបំពានលើកុមារចេញពីអ៊ីនធឺណិត។

យើងខ្ញុំសូមអំពាវនាវផងដែរដល់រដ្ឋទាំងឡាយ តាមរយៈយន្តការកិច្ចសហប្រតិបត្តិការអន្តរប្រទេស ប្រកបដោយប្រសិទ្ធភាព ឲ្យធានាឲ្យមានការស៊ើបអង្កេត និងផ្តន្ទាទោសជនល្មើសមិនថានៅទីកន្លែងណា និងសូមឲ្យពង្រឹងសមត្ថភាពបង្ក្រាបការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត ។

ភ័ស្តុតាងបង្ហាញថា តាមរយៈការការពារសិទ្ធិកុមារ និងអនុម័ត វិធានការ ដើម្បីបង្ក្រាបសកម្មភាពកេងប្រវ័ញ្ចលើកុមារនៅតាមអ៊ីនធឺណិត ការកាត់បន្ថយគ្រោះថ្នាក់ និងបរិស្ថានអ៊ីនធឺណិតមានសុវត្ថិភាព អាចនឹងសម្រេចទៅបានសម្រាប់កុមារទាំងឡាយក្នុងការអនុវត្តយ៉ាងពេញលេញនូវសិទ្ធិរបស់ពួកគេតាមអ៊ីនធឺណិត និងអហ្វឡាញ រួមទាំងសេរីភាពនៃការបញ្ចេញមតិរបស់ពួកគេផងដែរ។

យើងខ្ញុំត្រូវការអ៊ីនធឺណិតមួយដែលផ្តល់សិទ្ធិអំណាច មានលក្ខណៈទូលំទូលាយ និងប្រកបដោយសុវត្ថិភាព សម្រាប់កុមារទាំងអស់ មិនថាកុមារទាំងនោះនៅទីណាកន្លែងណាក៏ដោយ។ ចូរយើងទាំងអស់គ្នាភ្ជាប់ដោយសុវត្ថិភាព ដើម្បីធ្វើឲ្យអ្វីទាំងអស់នោះទទួលបានជោគជ័យ"។

ចប់

*ទិវា អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពជាងមុន ត្រូវបានប្រារព្ធធ្វើឡើងជាសកលក្នុងការជួយជម្រុញ ឲ្យមានការប្រើប្រាស់ប្រកបដោយសុវត្ថិភាព មានការទទួលខុសត្រូវ និងវិជ្ជមាននៃបច្ចេកវិទ្យាឌីជីថលសម្រាប់កុមារ និងយុវ*

*ជនវ័យក្មេង។ ទិវា នេះផ្តល់កាលានុវត្តភាពក្នុងការបង្ហាញឲ្យឃើញពីការប្រើប្រាស់ប្រកបដោយវិជ្ជមាននូវបច្ចេកវិទ្យា និងកំណត់ពីតួនាទីរបស់អ្នកពាក់ព័ន្ធនានា អាចធ្វើដើម្បីជួយដល់ការបង្កើតឲ្យមានអ៊ីធឺណិតប្រសើរជាងមុន និងសហគមន៍អ៊ីនធឺណិតមួយដែលមានសុវត្ថិភាពជាងមុន ។*

**តំណាងពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិទទួលបន្ទុកអំពើហិង្សាលើកុមារ**
*http://srsg.violenceagainstchildren.org/*

សូមឆែកមើលការសិក្សាថ្មីដែលធ្វើឡើងដោយតំណាងពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិ *Santos Pais* នៅលើ "*ការផ្តល់ព័ត៌មានជាសាធារណៈអំពី ហានីភ័យដែលអាចមាន និងការ កាត់បន្ថយហានិភ័យឲ្យមកនៅកម្រិតអប្បបរមា - ICTs អ៊ីនធឺណិត និងអំពើហិង្សាលើកុមារ*"

**អ្នករាយការណ៍ពិសេសស្តីពីការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្រ្តកុមារ៖**
*http://www.ohchr.org/EN/Issues/Children/Pages/ChildrenIndex.aspx*
*សូមឆែកមើលរបាយការណ៍ថ្មីស្តីពីរបៀបដែលត្រូវបង្ក្រាបការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត ដោយអ្នករាយការណ៍ពិសេស de Boer-Buquicchio ដែលនឹងត្រូវធ្វើបទបង្ហាញក្នុងខែមីនាដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖*
*http://www.ohchr.org/Documents/Issues/Children/SR/A.HRC.28.56_en.pdf*

***អ្នករាយការណ៏ពិសេសស្តីពីការលើកស្ទួយ និងការពារសិទ្ធិសេរីភាពនៃការសម្តែងមតិយោបល់៖***
*http://www.ohchr.org/EN/Issues/FreedomOpinion/Pages/OpinionIndex.aspx*
*សូមឆែកមើលរបាយណ៍ការចុងក្រោយបង្អស់ស្តីពីសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់កុមារ ដោយ អ្នករាយការណ៏ពិសេស Kaye ដែលនឹងត្រូវធ្វើបទបង្ហាញដល់មហាសន្និបាតអង្គការសហប្រជាជាតិ៖*
*http://ap.ohchr.org/documents/dpage_e.aspx?si=A/69/335*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក លោកស្រី Nekane Lavín តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៤ ០២) /*អ៊ីមែល៖ nlavin@ohchr.org / អ៊ីមែល៖ srsaleofchildren@ohchr.org) *និង លោកស្រី Elda Moreno តាមរយៈទូរស័ព្ទលេខ (+១ ៩១៧ ៥៣០៥៥៦១/*អ៊ីមែល៖ emoreno@unicef.org)

សម្រាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមកឈ្មោះ Xabier Celaya សិទ្ធិមនុស្ស អ.ស.ប អង្គភាពព័ត៌មានតាមរយៈ ទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣/ អ៊ីមែល៖ xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើបណ្តាញព័ត៌មានសង្គម ៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធ៊ឺ៖** http://twitter.com/UNrightswire

ហ្គោហ្គីល៖ **Google+** gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR
បរិយាយសាច់រឿង ៖ http://storify.com/UNrightswire
ផែនទីច្បាប់បរិវេណសិទ្ធិមនុស្សជាសកល ៖ http://uhri.ohchr.org/en